March 14, 2019

# ឯកអគ្គរដ្ឋទូតអឺរ៉ុបទើបចប់អាណត្តិ ថា ពន្ធលើអង្ករកម្ពុជានឹងមានការសម្រេចជាថ្មីបន្ទាប់ពី ៣ឆ្នាំ




ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា លោក ច្យច អេដហ្គា (George Edgar) [ឆ្វេង] ថ្លែងនៅក្នុងកម្មវិធីអបអរខួបទី២០ នៃកិច្ចព្រមព្រៀង សហប្រតិបត្តិការរវាងកម្ពុជា-សហភាពអឺរ៉ុប នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ នារាជធានីភ្នំពេញ។ RFA

*ដោយ មាន ឫទ្ធិ* RFA 2019-03-12

*ឯកអគ្គរដ្ឋទូតចប់អាណត្តិរបស់សហភាពអឺរ៉ុបប្រចាំកម្ពុជា លោក ចច អេដហ្គារ* (George Edgar) *ប្រាប់អាស៊ីសេរីតាមសារអេឡិចត្រូនិកនៅថ្ងៃអង្គារ ទី ១២ មីនា ថា គណៈកម្មការអឺរ៉ុប នឹងត្រូវធ្វើសេចក្ដីសម្រេចចិត្តជាថ្មីបន្ថែមទៀត ក្នុងរឿងយកពន្ធលើអង្ករកម្ពុជា បន្ទាប់ពីហួសរយៈពេលគិតពន្ធ ៣ ឆ្នាំដំបូង ដែលសហភាពអឺរ៉ុបទើបបានដាក់ចេញ។ លោក ចច អេដហ្គារ បដិសេធឆ្លើយតបនឹងសំណួរអាស៊ីសេរីថា តើលោកពិតជាបានសម្ដែងការសោកស្ដាយចំពោះរឿងសហភាពអឺរ៉ុបសម្រេចយកពន្ធលើអង្ករកម្ពុជានេះ ដូចតាមការផ្សាយរបស់សារព័ត៌មាន*

*ក្នុងស្រុកមែនដែរឬទេ ក្នុងជំនួបជម្រាបលារវាងលោក ជាមួយរដ្ឋមន្ត្រីកសិកម្ម លោក វេង សាខុន កាលពីថ្ងៃទី១១ មីនា។*

*យ៉ាងណាក៏ដោយ លោក ចច អេដហ្គារ គូសបញ្ជាក់ថា ក្នុងជំនួបនោះ ភាគីទាំងពីរ ពិតជាបានកត់សម្គាល់ ពីករណីដាក់ចេញវិធានការការពាររបស់សហភាពអឺរ៉ុប តាមរយៈការគិតពន្ធលើការនាំចូលអង្ករកម្ពុជា និងមីយ៉ាន់ម៉ា ឬភូមាជាផ្លូវការ ចាប់ពីថ្ងៃទី១៨ មករា ឆ្នាំ ២០១៩ តទៅ។ លោកថា វិធានការការពាររយៈពេលបីឆ្នាំដំបូងនេះ ធ្វើឡើងស្របតាមបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុបស្តីពី ប្រព័ន្ធអនុគ្រោះពន្ធទូទៅ GSP បន្ទាប់ពីមានបណ្តឹងពីរដ្ឋសមាជិករបស់អឺរ៉ុប ដោយសារតែមានការគំរាមកំហែងធ្ងន់ធ្ងរដល់សមត្ថភាពប្រកួតប្រជែងនៅទីផ្សារអឺរ៉ុប។ លោក ចច អេដហ្គារ បន្ថែមថា ក្នុងជំនួបនោះភាគីទាំងពីរក៏បានពិភាក្សាគ្នាជុំវិញសមិទ្ធផលនានាដែលក្រសួងសម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រោមកម្មវិធីកិច្ចសហប្រតិបត្តិការយូរអង្វែងរវាងសហភាពអឺរ៉ុប និងក្រសួងកសិកម្ម។*

*កម្ពុជា ត្រូវខាតបង់យ៉ាងហោចណាស់ជាង ៥០លានដុល្លារក្នុងមួយឆ្នាំៗ ពីការតម្រូវឱ្យបង់ពន្ធលើការនាំចូលអង្ករទៅកាន់សហភាពអឺរ៉ុប។*